www.khmerpostusa.com

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

KhmerPost USA

Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies

Vol. 13. Issue #304

Nov 12Th, 2020

Office: 978-677-7163

Direct: 978-656-8141

Email:Khmerpostusa@gmail.com

# អបអរលោក ជោ បាយដិន ជាប្រធានាធិបតីថ្មីចាប់ពី២០២១

**ដោយ ពិន សំខុន**

លទ្ធផលនៃការបោះឆ្នោតថ្ងៃទី៣វិច្ឆិកា ២០២០ បានឱ្យលោក ជោ បាយដិន ជាអ្នកឈ្នះ ជាប្រធានាធិបតីជំនួសលោក ឌុណល ត្រាំ ហើយ នឹងលោកស្រី កាម្លា ហារីស ជាអនុប្រធានាធិបតី ជំនួសលោក ម៉ាយ ផែន ដែលអាណត្តិថ្មីផ្តើមនៅ ថ្ងៃទី២០មករាឆ្នាំ២០២១។

**ថ្ងៃទី៣ វិច្ឆិកា ២០២០**

អ្នកបោះឆ្នោតបានមកឈរចាំវេនខ្លួនចូល បោះឆ្នោត"កន្ទុយរង់ចាំ"បោះឆ្នោតយ៉ាងវែង ដែលផុំឡើងជាច្រើនកន្លែងតាំងពីព្រលឹម។ ប៉ុន្តែ អ្នកបោះឆ្នោតខ្លះទៀតបានបោះឆ្នោតរួចហើយ តាំងពីច្រើនថ្ងៃមកហើយ ដោយការបោះឆ្នោត ផ្ញើរតាមសំបុត្រ ដែលចំនួននោះមានដល់ទៅ ៩៧លាននាក់ ជាចំនួនច្រើនបំផុតមិន ដែលមាន ពីមុនមក ដោយសារសហរដ្ឋអាមេរិកនៅក្នុង ស្ថានភាព"អាសន្ននៃកូវិដ១៩"។


ជីល និង ជោ បាយដិន និងទៅកាន់សេតវិមាន

លទ្ធផលមិនទាន់ចេញមកភ្លាម១ដូចធម្មតាទេ ពីព្រោះតែ"ឆ្នោតផ្ញើរសម្លេង"មានច្រើន ពេក(ជិត១០០លានសន្លឹក) ម៉ោង២ទៀបភ្លឺនៃ ព្រលឹម ទី៤វិច្ឆិកា លោក ត្រាំ ចេញមកប្រកាស ថា"លោកជាអ្នកឈ្នះ!" ប៉ុន្តែលោក បាយដិន ប្រកាសថ្ងៃដដែលថា"យើងនៅលើផ្លូវដែលឈ្នះ" ហើយ - ពេលនោះអ្នកសារព័ត៌មានដ៏សន្ធឹកសន្ធាប់ ជាងពេលណាទាំងអស់បានកត់ត្រាចំនួន"ដំណាង ពីរដ្ឋនិមួយ១"ដែលបានរាប់ជាសម្រេចហើយ នោះថា" "បាយដិន២២៣ នឹង ត្រាំ២១៣""ពេល នោះរដ្ឋ"អារីហ្សូណា"រដ្ឋដ៏លំបាកសម្រាប់ ជោ បាយដិន ទើបនឹងនឹងធ្លាក់ទៅក្នុងដៃនៃគណបក្សប្រជាធិបតេយ្យជាលើកដំបូង គឺគិតតាំងពីជំនាន់ លោក គ្លីងតុន មកម្លេះ។

**គេសង្ឃឹមថា:** លទ្ធផលថានរណាជា"អ្នក ឈ្នះជាស្ថាពរ"នោះ នឹងអូសបន្លាយទំនងជាដល់ ១០ថ្ងៃក្រោយយ៉ាងតិច ប្រសិនបើ ឌុណល ត្រាំ នឹងមិនធ្វើការប្តឹងផ្តល់ នៅពេលខ្លួនចាញ់ទេនោះ,

**តទៅទំព័រទី ០៤**






# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, **M.D.**

**Sokharith Mey, M.D.**

លោក ឆាន់ ទូច , **C.N.P.**

**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ

***Family Medicine*** &

សុខភាពផ្លូវចិត្ត

***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking




## យើងទាំងអស់គ្នាមានតួនាទីធ្វើឱ្យសហគមន៍របស់យើងមានសុខភាពល្អ

ជាមួយនឹងទីភ្នាក់ងារ **Health Connector** អ្នកអាចរកបានការធានារ៉ាប់រងគុណភាពខ្ពស់ បូករួមនឹងគម្រោងចំណាយទាប ឬគ្មានការចំណាយតែម្តង នៅទីកន្លែងតែមួយ។ គ្រប់គម្រោងទាំងអស់តាមរយៈទីភ្នាក់ងារ Health Connector ធានារ៉ាប់រងទៅលើអត្ថប្រយោជន៍សំខាន់ៗ ដូចជា៖ ▶ ការទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ▶ សេវាកម្មសង្គ្រោះបន្ទាន់ ▶ ការស្នាក់នៅមន្ទីរពេទ្យ ▶ ការថែទាំពេលមានផ្ទៃពោះ និងទារកទើបកើត ▶ សេវាកម្មស្ភានីតិសម្បទា ▶ ការពារ និងសុខុមាលភាព ▶ សេវាកម្មមន្ទីរពិសោធន៍ ▶ សុខភាពផ្លូវចិត្ត និងការញៀនថ្នាំ ហើយជាច្រើនទៀត។

**www.MAhealthconnector.org**
**1-877-623-6765 | TTY 1-877-623-7773**

ត្រូវការជំនួយក្នុងការចុះឈ្មោះមែនទេ? សូមទូរស័ព្ទដើម្បីណាត់ជួបជាមួយមជ្ឈមណ្ឌលនៅក្នុងតំបន់របស់អ្នក

**Lynn Community Health Center**
781-581-3900
269 Union St, Lynn, MA 01901

**Boston Public Health Commission**
1800-847-0710 | 617-534-5050
1010 Massachusetts Ave, Boston, MA 02118

**Greater Lawrence Community Action Council**
978-620-4784
305 Essex St, Lawrence, MA 01840

តមកពីទំព័រទី ០១

# អបអរសាទ ជោ បាយដិន ជាប្រធានាធិបតី

បើមិនដូច្នោះទេ នៅ៤១ថ្ងៃក្រោយរដ្ឋនិមួយៗនឹងតែងតាំង"ដំណាងដោយខ្លួនឯង"បាន ។

លទ្ធផលមិនបានចេញមកដូចថ្ងៃមុនទេ ដោយលោកប្រធានាធិបតី បានផ្តើមប្តឹងពិការបោះឆ្នោតថា"មិនមានការគោរពច្បាប់ត្រឹមត្រូវទេ"តែពុំមានភស្តុតាងណាមួយទៅបង្ហាញតុលាការទេ ។ បាតុកម្មទាំងក្រុមការពារ"បាយដិន"ទាមទារឱ្យរាប់បន្តនៅកន្លែងរាប់សន្លឹកឆ្នោតជាច្រើនកន្លែងនឹងក្រុមលោក ឌុណល ត្រាំ នៅប្រឈមមុខសង្គ្រឹតដាក់គ្នា ប៉ុន្តែកងរក្សាសន្តិសុខនៅជុំជិតនៅឡើយ ។ គេនឹកថាមិនយូរមិនឆាប់នឹងមានការវាយតប់គ្នាជាមិនខាន ជាពិសេសនៅពេលប្រកាសលទ្ធផលឆ្នោតប្រធានាធិបតី ។

ទង្វើមិនទំនងនេះបានធ្វើឱ្យបែកបាក់គណបក្សសាធារណរដ្ឋជាពីរក្រុម ដែលខ្លះត្រូវតែដកខ្លួនថយចេញមួយរយៈពី ឌុណល ត្រាំ ដើម្បីឱ្យខ្លួនឯងជាព្រឹទ្ធសមាជិកអាចបោះឆ្នោតជាប់ ដូចជាលោកស្រីព្រឹទ្ធសមាជិក ខលីន នៅរដ្ឋម៉ែន ជាដើម ខ្លះទៀតដើរតាម ត្រាំ រហូត ។ រដ្ឋ៥ដែលមានសន្លឹកឆ្នោតប្រកៀកគ្នាមិនបានបញ្ឈប់ការរាប់សន្លឹកឆ្នោតទេ រីឯលទ្ធផលដែលចេញមកយឺតពេលបន្តិចបង្ហាញថា:

**១**-រដ្ឋផែនស៊ីវេនា ( មានដំណាង២0) បាយដិន បាន ៤៩,៤% - លោក ត្រាំ បាន ៤៩,៤% ( បាយដិនឈ្នះបាន៨,៨៧៣ សម្លេង)

**២**-រដ្ឋណេវ៉ាដា ( មានដំណាង៦នាក់) បាយដិន បាន ៥0% - លោក ត្រាំ បាន ៤៨% ( បាយដិន ឈ្នះ ២២,២0៩ សម្លេង)

**៣**-រដ្ឋ ជ័រចា ( មានដំណាង ១៦) បាយដិន បាន ៤៩+% - លោក ត្រាំ បាន ៤៩% ( បាយដិន ឈ្នះ ១,៥៨៧ សម្លេង)

**៤**-រដ្ឋអារីហ្សូណា( មានដំណាង១១) បាយដិន បាន ៥0) - លោក ត្រាំ បាន ៤៨,៦% ( បាយដិន ឈ្នះ ៤៣,៧៧៩ សម្លេង)

**៥**-រដ្ឋណតការ៉ូឡាយណា( ដំណាង១៥) បាយដិន បាន ៤៩% -លោក ត្រាំ បាន ៥0% ( ត្រាំ ឈ្នះ ៧៦,៧៣៧ សម្លេង) ។

លទ្ធផលនេះកំពុងតែរាប់បញ្ចប់( សន្លឹកឆ្នោតតិចជាង១0%) គេអាចឃើញថា លោក បាយដិន បាន២៦៤ហើយ នៅសល់ទេរដ្ឋ១-២ទៀតប៉ុណ្ណោះ នឹងបានឈ្នះហើយ -រីឯលោក ត្រាំ បាន២១៤ហើយ) នៅសល់៣-៤រដ្ឋទៀត ទើបបានគ្រប់ចំនួន។

ប៉ុន្តែគ្រាន់តែ៥ថ្ងៃប៉ុណ្ណោះ គឺថ្ងៃទី៧ វិច្ឆិកា ការរាប់សន្លឹកឆ្នោតជិត១00លានសន្លឹកបានផ្តល់លទ្ធផលជាស្ថាពរលើសពី២៧0:

**១**-ជោ បាយដិន -កាម្លា ហារីស ឈ្នះបានដំណាងរដ្ឋ ២៩0

**២**-ឌុណល ត្រាំ - ម៉ាយ ផែន បានសម្លេងដំណាងរដ្ឋ ២១៤

នៅមានលទ្ធផលមិនបានចេញមកដូចថ្ងៃមុនទេ ដោយលោកប្រធានាធិបតី បានផ្តើមប្តឹងពីការបោះឆ្នោតថា"មិនមានការគោរពច្បាប់ត្រឹមត្រូវទេ"តែពុំមានភស្តុតាងណាមួយ ទៅបង្ហាញតុលាការទេ ។ បាតុកម្មទាំងក្រុមការពារ"បាយដិន"ទាមទារឱ្យរាប់បន្តនៅកន្លែងរាប់សន្លឹកឆ្នោតជាច្រើនកន្លែងនឹងក្រុមលោក ឌុណល ត្រាំ ទាមទាឱ្យ"បញ្ឈប់ការរាប់សន្លឹកឆ្នោតបន្ត"នៅប្រឈមមុខសង្គ្រឹតដាក់គ្នា ប៉ុន្តែកងរក្សាសន្តិសុខនៅជុំជិតនៅឡើយ ។ គេនឹកថាមិនយូរមិនឆាប់នឹងមានការវាយតប់គ្នាជាមិនខាន ជាពិសេសនៅពេលប្រកាសលទ្ធផលឆ្នោតឱ្យប្រធានាធិបតីណាមួយឈ្នះ។

"ទង្វើមិនទំនង"របស់ប្រធានាធិបតី ត្រាំ នេះបានបន្តធ្វើឱ្យបែកបាក់សាមគ្គីក្នុងគណបក្សសាធារណរដ្ឋជាបន្តរទៅទៀត ជាពីរក្រុម ដែលខ្លះត្រូវតែដកខ្លួនថយចេញមួយរយៈពី ឌុណល ត្រាំ រួចទៅហើយមាន: អតីតប្រធានាធិបតី ប៊ូស, អតីតបេក្ខជនប្រធានាធិបតី រ៉មនី, គ្រួសារសពបេក្ខជនប្រធានាធិបតី ជន ម៉ាកេន, លោកអតីតរដ្ឋលេខា ផវែល, អតីតរដ្ឋលេខា រ៉ាយស៏...។ ប្រធានាធិបតីចាស់ទាំងអស់ ដែលនៅរស់នៅឡើយ គេឈរខាងលោក ជោ បាយដិន ទាំងអស់ទៅហើយ។

**ទស្សនៈនយោបាយសហគមន៍ខ្មែរ-អាមេរីកាំង**

មានបងប្អូនខ្មែរជាច្រើន ដោយសារតែចង់ឱ្យសហរដ្ឋអាមេរិក ទៅជួយកម្ពុជាឱ្យចម្រុងចម្រើនដោយលទ្ធិប្រជាធិបតេយ្យ ក៏នាំគ្នាចេញទៅជួយឃោសនាដល់បេក្ខជនប្រធានាធិបតី-ទាំង២ ។ នាតំបន់ឡុងប៊ិចនឹងឆ្នេរខាងលិច ដែលប្រមូលផ្តុំសហគមន៍ប្រមាន១0ម៉ឺននាក់ ច្រើនប្រកាន់យកលោក ឌុណល ត្រាំ រីឯឆ្នេរខាងកើតនៃសហរដ្ឋ មានឡូវែល លីន វីវែរ រ៉ូដអាយឡិន... ដែលមានគ្នាប្រមាណ៦-៧ម៉ឺននាក់ដែរភាគច្រើនប្រកាន់យកលោក ជោ បាយដិន ប៉ុន្តែបើទោះជាទទួលបានលទ្ធផលយ៉ាងណានោះ ពួកគេនឹងមិនបាក់បែកគ្នាជាបក្សពួកទេ។ ពួកគេសង្ឃឹមថា"សហរដ្ឋអាមេរិកនឹងចូលទៅជួយសង្គ្រោះកម្ពុជា"ប៉ុន្តែពុំដឹងជារបៀបណានោះទេ?

កម្ពុជាជាប្រទេសអាស៊ាន ដែលមានទំនោរទៅកាពារផលប្រយោជន៍ប្រទេសចិនជាមួយនឹងឡាវខុសពីប្រទេស៨ទៀត។ ហើយតាំងពីដើមអាណត្តិនៃលោក ត្រាំ មកអាមេរិកបាន: **១**-ដកសម្ព័ន្ធភាពចេញពីអាស៊ាន( អាស៊ាន១១ប្រទេស) **២**-ចេញពីអាស៊ីប៉ាស៊ីហ្វិក( មានជប៉ុន-កូរ៉េខាងត្បូង-តៃវ៉ាន់...) នឹង **៣**-ចេញពីសមុទ្រឬឥណ្ឌា( ឥណ្ឌា-អូស្រ្តាលី-ប៉ាគិស្ថាន...) ដែលធ្វើឱ្យប្រទេសទាំងនោះកំព្រា ក្នុងការទប់ទល់នឹងចិន ដែលបានបញ្ជូនទ័ពនឹងបើកផ្លូវសេដ្ឋកិច្ចវាទទីតម្លើងឥទ្ធិពលចិនកុម្មុយនីស្តនៅស្ទើរគ្រប់តំបន់ ដែលលែងមានប្រទេសណាហ៊ានក្អកឡើយ។ អាមេរីកាំងមិនមានឥទ្ធិពល នៅអាស៊ីប៉ាស៊ីហ្វិក ដូចពីមុនទៀតទេ ពីព្រោះទ័ពអាមេរីកាំង ជាទ័ពប្រទេសប្រជាធិបតេយ្យចេញបង្ក្រាបសត្រូវជាមួយសម្ព័ន្ធមិត្តនឹងជាមួយអង្គការសហប្រជាជាតិ ទើបមានប្រសិទ្ធិភាព ។

សង្ឃឹមថាលោក ត្រាំ ត្រឡប់ទៅជួយខ្មែរនោះនៅពេលជាប់ឆ្នោតសារជាថ្មីគឺជាការ"វិនិច្ឆ័យភាន់ច្រឡំ"បើតាមមេបញ្ជាការជើងទឹកអាមេរីកាំង ពីព្រោះ លោកត្រាំ **១**-បានទៅជួយវៀតណាមតែម្នាក់ឯង កាលពីឆ្នាំ២០១៧ **២**-អាណត្តិនេះជាអាណត្តិរបស់ ត្រាំ ដែលធ្វើអ្វីសម្រាប់តែការគិតរបសខ្លួនម្នាក់ឯងពុំមែនជារបស់គណបក្សសាធារណរដ្ឋទៀតទេ។

ផ្ទុយទៅវិញលោក បាយដិន ពុំមែនជាមនុស្សនៅក្រៅបក្សប្រជាធិបតេយ្យទេ លោកបាននិយាយថា"លោកនឹងត្រឡប់ ទៅកន្លែងដែល ត្រាំ បានថយចេញ ដូច្នេះវានឹងមានកម្ពុជាជាដើម, **តទៅទំព័រទី ១២**





ព្រឹទ្ធសមាជិក ស៊ូសាន ខលីង
គណបក្ស សាធារណរដ្ឋ



# Massachusetts Health Connector Open Health Insurance Enrollment Period Begins November 6, 2020 - January 23, 2021

By Khmer Post USA

October 22, 2020 – Recognizing the need for expert assistance is higher than ever, the Massachusetts Health Connector has 18 community-based Navigator organizations ready to provide health insurance enrollment help to residents, including 10 with newly-expanded capacity to provide additional support during the COVID-19 pandemic.

With the 18 Navigator organizations and 100 people working as Navigators, this is the largest Navigator program in Massachusetts since its inception for 2014 Open Enrollment as part of the Affordable Care Act. Navigators traditionally provide direct, in-person assistance to residents in their communities who need help accessing Health Connector coverage. As the Health Connector enters Open Enrollment for 2021, many Navigators will be providing virtual assistance to supplement more limited in-person help due to COVID-19.

"Having access to knowledgeable, experienced help is more important than ever for people who need Health Connector coverage going into 2021," said Louis Gutierrez, the Executive Director of the Massachusetts Health Connector. "Our Navigators have substantial impact, helping thousands of Health Connector members and new applicants every year, and their services are all the more necessary amid this year's pandemic challenge. They are here to deliver quality, affordable health coverage to the people they serve."

During Open Enrollment, anyone without health insurance can enroll into coverage for 2021. This includes people who may have lost their job and work-based health insurance in 2020 and have been without coverage. Additionally, people who may have enrolled in COBRA coverage after losing a job this year can apply for coverage and find out if they qualify for subsidized coverage through the Health Connector, which through the ConnectorCare program provides plans with reduced premiums and co-pays, and no deductibles – and will likely be far more affordable than COBRA plans.




MA Health Connector press conference with elected officials from Lynn and Lawrence. In attendance were Mayor Thomas McGee and Rep. Ehrlich in Lynn; Rep. Minicucci, and Rep. Danvers in Lawrence and Navigators from around commonwealth to discuss the covid-19 assistance for health insurance enrollment.

By working with a Navigator, Health Connector members and applicants are able to tap into a broad range of help, including completing an application, guidance on plan selection, providing documentation as necessary, and help throughout the year when members have questions about their coverage or Health Connector account. These services help people get into coverage and help make sure they stay covered, and Navigators provide these services in a range of languages and in ways designed to support the diverse populations of the Commonwealth.

All 16 organizations from the last two-year Navigator cycle return for the new round that runs through June 2022, along with two organizations: Lynn Community Health Center and Community Health Programs, which is headquartered in Great Barrington. The organizations will house Navigators in 32 location, and can provide assistance in a total of 23 languages. Massachusetts residents can learn more about the Navigator program and find Navigators and other assisters in their community at the Health Connector website.

Due to COVID-19, the Health Connector's walk-in centers remained closed. In order to help applicants and members who rely on the walk-in center for support, the Health Connector is providing additional capacity opportunities at 10 Navigators, which will maintain additional support through September 2021. These Navigators will provide additional staff and hours to support people who need help or have questions about their coverage.

Here is a list of the 2020-22 Navigators, including total grant award amount for 2020-21 (also including funding for expanding capacity through September 2021), locations with high density of Khmer language speaking community are encourage to utilize their services:

Family Health Center (Worcester) ($285,201), 26 Queen St., 162 Chandler St., Worcester; 32 Orchard St., Southbridge. Languages: Albanian, Arabic, Berber, French, German, Greek, Italian, Kaba, Nepali, Sango, Spanish, Portuguese, Vietnamese. This organization will provide additional support.

Greater Lawrence Community Action Council, Inc. ($183,727), 305 Essex St.. Languages: Spanish. This organization will provide additional support.

Lynn Community Health Center ($100,000), 269 Union St. Languages: Spanish, Portuguese, Khmer, Russian


ការិយាល័យច្បាប់
រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា



Andrew 'Bunna' Taing, Esq.
មេធាវី អែន ទ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

តំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទំនាស់ផ្នែកអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com





CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខ័យ (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការលក់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY
INSURANCE AGENCY

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# ទ្វារមួយបិទទ្វារមួយទៀតបើក: បរិបូ ភារៈ ហាងទំនិញ និងបម្រើសេវាទីក្រុងឡូវែលកម្ពុជាសូមស្វាគមន៍!

**ថ្ងៃទី០២ វិច្ឆិកា ឆ្នាំ២០២០**

ដោយ: សុបិន ពិន

ទីក្រុងឡូវែលៈ ផ្លាស្យាប៉ៃលិនដ៏ល្បីឈ្មោះស្ថិតនៅតាមដងផ្លូវ មីតឌុលស៊ិច (Middlesex)បានបន្ថែមហាងស្រស់ថ្លាថ្មីមួយឈ្មោះថាៈ **បរិបូ ភារៈ ហាងទំនិញ និងបម្រើសេវា** ជូនដល់ប្រជាជនកម្ពុជា។ សហគ្រិនពីររូបបានផ្តួចផ្តើមគំនិតនេះ ឡើង អ្នកមីងឈ្មោះ មេលីស្សា លក្ខិណាសយ មកពីទីក្រុងលីន (Lynn) និងក្មួយស្រីឈ្មោះ សានីយ៉ា ស៊ុម មានកំណើតនៅក្រុងឡូវែល គឺជាគ្រូបង្រៀនភាសាអង់គ្លេស នៅសាលា Samoset Middle School ក្នុងក្រុង Leominster បានចាប់ដៃគ្នាបើកហាងទំនិញ និងបម្រើសេវាតាមប្រពៃណីខ្មែរក្នុងអំឡុងពេលរីករាលដាននៃមេរោគកូវីដ-១៩។




*រូបពីឆ្វេងទៅស្តាំ: សាត សយ អេជីលីណា ផប ហឿន ហេង សារ៉ា សាន មេលីហ្សា សយ រឿន សាន រឿន ង៉ា រីហន សយ សារិន សាំង ខូវី រឿន សានីយ៉ា ស៊ុម សុខធា សា អែយ៉ាណា បិតចិនខត សាសហ្សា សយ*
*ថតរូបដោយ: សុបិន ពិន*

**បរិបូភារៈ** គឺជាការចាប់កំណើតឡើងវិញនៃហាងទំនិញឈ្មោះ អមរា បូទិក Amara Boutique គឺជាហាងទំនិញល្បីឈ្មោះមួយដែលបានបង្កើតឡើងនៅឯផ្លាស្យាប៉ៃលិនអស់រយៈពេលជាងមួយទសវត្សន៏កន្លងមក។ វាត្រូវបានចុះផ្សាយដោយទស្សនាវដ្តីយ៉ាងគឺ Yankee Magazine លេខចុះខែឧសភា ឆ្នាំ២០២០ ថា ជាគោលដៅមួយគួរជាទីចង់ទស្សនានៅក្នុងក្រុងឡូវែលកម្ពុជា។ ក្រោយមកការរីករាលដាលបានវាយលុកយ៉ាងខ្លាំង និងបានបង្ខំចិត្តបិទទ្វារអាជីវកម្ម។



*មេលីស្សា សយ និងសានីយ៉ា ស៊ុម ម្ចាស់ ហាង បរិបូភារៈ ទាំងពីរនាក់កំពុងលើកកែវស្រាសំប៉ាញឡើងជាមួយមិត្តភ័ក្តិ និងក្រុមគ្រួសារ។ ថតរូបដោយ: សុបិន*

"សូមអញ្ជើញអ្នកទាំងអស់គ្នា" សានីយ៉ា និយាយ។ ឥឡូវនេះ អត់មានអ្នកធ្វើដំណើរទេ ហើយពិធីអាពាហ៍ពិពាហ៍ទាំងអស់ក្នុងឆ្នាំនេះ បានផ្អាករហូតដល់ឆ្នាំក្រោយ។ **តទៅទំព័រទី ០៧**






តមកពីទំព័រទី ០៦

# បរិបូ ភារៈ ហាងទំនិញ និងបម្រើសេវា...

មិនមានភាពប្រាកដប្រជាថាតើឆ្នាំក្រោយនឹងទៅជាយ៉ាងណាទេ ។ "ប៉ុន្តែប្រសិនបើអ្នកមិនដាក់ជើងក្នុងទឹកទេ អ្នកមិនដឹងថា ទឹកនោះវាជ្រៅប៉ុនណាដែរ" លក្ខិណា និយាយ ។ លក្ខិណា បានមកសហរដ្ឋអាមេរិក ជាកុមារជនភៀសខ្លួនទើបមានអាយុ១០ឆ្នាំ រស់នៅស៊ីអាថល Seattle រដ្ឋវ៉ាស៊ិនតុន នាងបានរៀបការ និងមានវាសនា មកដល់ទីក្រុង Lynn នៅក្នុងឆ្នាំ១៩៩៦ ។ ក្រោយមកទៀត នាង គឺជាអ្នកសំអាងតុបតែងមុខសម្រាប់អ្នករៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ អស់រយៈពេល ២០ ឆ្នាំ ។ "ខ្ញុំស្រឡាញ់វប្បធម៌ខ្មែរ និងកម្រមានឱកាសណាស់"នាងនិយាយ ។



*ការរៀបចំបើកសម្ពោធហាង ថតរូបដោយ: សុបិន*

ទាំងពីរ មីង និងក្មួយស្រី បានតុបតែងហាង អមរា បូទិក យ៉ាងរុងរឿងគួរជាទីពេញចិត្ត មើលទៅទំនើបកម្រាលឥដ្ឋក្រាលឈើថ្មីស្រឡាង បន្ថែមពន្លឺចែងចាំងរចនាម៉ូតថ្មី១០០% ពីក្រោមដល់លើ ហាងបូទិកកំពុងដង្ហោយហៅអ្នកដើរទិញឥវ៉ាន់សម័យថ្មី ។ តាមជួរ និងតាមខ្នង់ សំលៀកបំពាក់បុរសខ្មែរ រហូតដល់សំលៀកបំពាក់ប្រពៃណីនារីខ្មែរ ដង្កៀបសក់ រូបចម្លាក់ធ្វើពីឈើប្រណីតផលិតនៅប្រទេសកម្ពុជា ចំណងជើងហាងកំណត់អត្ថន័យថា បរិបូភារៈ មានន័យជាភាសាខ្មែរថា "សម្បូរណ៍របស់សព្វយ៉ាង" គឺជាឈ្មោះដែលព្រះសង្ឃខ្មែរបានប្រោះព្រំប្រសិទ្ធិពរជ័យ ។



*មោទនភាពទង់ជាតិខ្មែរ និងរបស់ជាច្រើន ថតរូបដោយ: សុបិន*

ចាប់ផ្តើមបើកដំបូងបានល្អ ។ ពូនាងបានប្រាប់នាងថា នាងគួរតែអុជធូបប្រាំសរសៃក្នុងមួយថ្ងៃរៀងរាល់ពេលព្រឹកនៅពេលនាងមកធ្វើការ ។ នេះគឺជាប្រពៃណីសុំពរជ័យរាល់ថ្ងៃសម្រាប់អាជីវកម្ម ។ មានការចូលរួមជុំជិតដោយក្រុមគ្រួសារ និងមិត្តភ័ក្តិកាត់ខ្សែបូរ និងគាស់ស្រាសាំប៉ាញអម ដោយសម្លេងស្រែកអបអរ "លុយ លុយ" ។



អាវប្រពៃណីខ្មែរ សម្រាប់បុរស និងក្មេងប្រុស (ធ្វើខាងលើ)



សំលៀកបំពាក់ប្រពៃណីខ្មែរ សម្រាប់ស្ត្រី



ការតាំងបង្ហាញសំលៀកបំពាក់សម្រាប់ក្មេងស្រីជាតិ



សៀវភៅភាសាខ្មែរច្រើនប្រភេទ



រូបចម្លាក់ខ្មែរធ្វើពីឈើ



កាបូប ក្រមាខ្មែរ ធ្វើពីសូត្រ



មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហេិល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

# មិត្រភក្តិរបស់អ្នក គឺ សំខាន់។

# ការពារ គ្រួសាររបស់អ្នក ក៏យ៉ាងដូច្នេះដែរ



អ្នកប្រហែលជាមិនបានព្រួយបារម្ភ អំពីការឆ្លងវាទេ ប៉ុន្តែ អ្នកអាចមានមេរោគវីរុស និងចំឡងវាទៅមនុស្សដែលអ្នកស្រឡាញ់ - សូម្បីតែអ្នកមិនឈឺថ្កាត់ក៏ដោយ។

## អ្នកមានអំណាច ដើម្បីបញ្ឈប់ការឆ្លងរាលដាល។

- រក្សាចំងាយរបស់អ្នក។
- ពាក់ម៉ាស្ក។
- លាងដៃរបស់អ្នក។
- តើមិនស្រួលខ្លួនឬ? ចូរធ្វើតេស្តឥតគិតថ្លៃ។

ស្វែងយល់ថែមទៀតនៅ Mass.gov/បញ្ឈប់COVID១៩

# Major Cambodian American Victories in 2020 US Elections

## *First Two Khmer Women Elected to State and Local Offices*

By Soben Pin

Boston, MA—The 2020 US Elections made history. Republicans and Democrats struggle in a tight race. For Cambodian Americans, there are two definite victories: the first Khmer woman elected to the State House Representative Vanna Howard, and the first Cambodian American and first Khmer woman elected to the City Council in Long Beach, California. This election is a big milestone for Cambodian American history.

The United States Presidential race gave a victory to Democrat Joe Bidden on Saturday night, 5 days after the election, as key states flipped Blue. At 264 electoral votes, Bidden needed only 6 more electoral votes to win his presidency. Pennsylvania turned blue late Saturday by a small margin of 60,233 votes or (49.9% vs. 49.0%) and resulted in Joe Bidden becoming the next president of the United States. President-Elect Joe Bidden and Vice President-Elect Kamala Harris delivered the victory speech in Wilmington, Delaware.



President Donald J. Trump, President-Elect Joe Bidden



Long Beach City Council-Elect
Dr. Suely Saro



MA State Rep-Elect
Vanna Howard



Credit AP

President-Elect Joe Bidden and Vice President-Elect Kamala Harris

In the following days, Bidden won a few more states. Now President-Elect Joe Bidden has a majority of 291 electoral votes, however, President Trump still have not conceded.

President Trump also filed several lawsuits in key states as the election results were narrow in Pennsylvania, Georgia, Michigan, and Nevada in an effort to contest the election results. Many lawsuits were thrown out of the courts. In his tweet, Joe Bidden said that he “ran the campaign as a proud democrat but he will be the American President”. President Trump held a press conference on the 3rd day after the election and said that there was voter suppression, and voting irregularity and he will protect the American legal votes. And he tweeted that he “won the campaign by large” on the same day Bidden declared his victory, twitter flagged the president’s post for the first time in 4 years of his presidency.

Meanwhile, Massachusetts voted 65% for Bidden, and also elected the first Khmer Woman to the State House Representative. Vanna Howard will represent district 17, which includes part of downtown Lowell and Chelmsford.

In Long Beach, California, first of the first. First Cambodian American and first Khmer woman also was elected to the City council in Long Beach, Dr. Suely Saro, for the 6th District. She beat a powerful Vice Mayor Dee Andrew by over 60% of the votes (7,528 votes vs. 5,047 votes).

The 6th District includes Signal Hill and part of Cambodia Town in Long Beach. District 6 is not where the majority Cambodian Americans live; however, Dr. Suely Saro ran an aggressive campaign since the beginning that put her in position to win by rallying all local officials, democrats, clubs organizations, and labor unions endorsements, racking up to more than 2 dozen endorsements, including Senator Bernie Sander.

Vanna Howard on the other hand, is an experienced politician having worked with Congresswoman Niki Tsongas for more than 10 years as the Regional Director, serving over 800 thousands people in the 3rd congressional district of Massachusetts. Dr. Suely Saro on the other coast, worked with former State Senator Ricardo Lara that paved her the way to the 6th district and L.A. region. She also served as the Chairperson of Long Beach’s Citizen Police Complaint Commission, and currently is a professor at Cal State, Los Angeles.

The 2020 U.S presidential election is a remarkable year for Cambodian Americans as the first two Khmer women are elected to the highest public offices and they make history.

PRINT READERSHIP
50,000 Monthly / 600,000 Annually
Plus additional exposure in our online editions at khmerpostusa.com

KhmerPost USA

ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM

2020 PRINTING SCHEDULES
EFFECTIVE FEBRUARY 1, 2020

ADVERTISING RATES AND SIZES
All ads are printed in Full Color

| Ad Size (WxH) | 1 Issue 5% Savings | 3 Months (6 Issues) 7.5% Savings | 6 Months (12 Issues) 10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| Full (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| 1/2 (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| 1/4 (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| 1/8 (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

Your ad is also published in our online editions of the newspaper at khmerpostusa.com




MONTHLY DISTRIBUTION
70+ Locations in Lowell, MA · 7,000 copies
25 Locations in Lynn & Revere, MA · 1,000 copies
25 Locations in Providence & Cranston, RI · 2,000 copies
Additional distribution online

Khmer Post USA
Distribution Locations Include:
Households • Markets • Retail Businesses
Restaurants • Office Buildings • Government Offices
Chamber of Commerce • Buddhist Temple
Laundromats • And Much More

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

Advertising deadlines are 5 business days prior to printing date.

CONTACT INFO
27 Jackson Street • Unit 329 • Lowell, MA 01852
Tel: 978.677.7163 • Fax: 978.677.7092
Email: khmerpostusa@gmail.com
www.khmerpostusa.com

Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau

Follow us @KhmerPostUSA

Follow us @KhmerPostUSA

# ឌឹ ឃេមបូឌា ដេលី The Cambodia Daily

**អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃេមបូឌា ដេលី**

## លោក ហ៊ុន សែន និងមនុស្សជិត១ពាន់នាក់ទៀតធ្វើតេស្តរកកូវីដ១៩ ជាលើកទី២

By ឌឹ ខេមបូឌា ដេលី

- November 10, 2020

ក្រសួងសុខាភិបាលនៅថ្ងៃច័ន្ទ ទី០៩ ខែវិច្ឆិកានេះឱ្យដឹងថា លទ្ធផលពីការធ្វើតេស្តជាលើកទី២ ចំពោះអ្នកដែលប៉ះពាល់ដោយផ្ទាល់ជាមួយរដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសហុងគ្រីលោក ភីធើស៊ីចាតូ កាលពីថ្ងៃទី០៣ ខែវិច្ឆិកា បានរកឃើញមនុស្ស៣នាក់ ឆ្លងជម្ងឺកូវីដ១៩។

មន្ត្រីទាំងបីនាក់នោះរួមមានលោក សួស ទី២ នេះ រួមមាននាយករដ្ឋមន្ត្រី ហ៊ុន សែន ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេសលោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទលោក វេង សាខុន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មលោក ប៉ាន់ សូរស័ក្តិ និងលោក លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក ព្រមទាំងទាំងមន្ត្រីជាន់ខ្ពស់ក្រុមអង្គរក្ស និងក្រុមអ្នកសារព័ត៌មានជាតិ-អន្តរជាតិផងដែរ។

ការធ្វើតេស្តជាទ្រង់ទ្រាយធំនេះ ក្រោយពេលក្រសួងសុខាភិបាលរកឃើញថាអង្គរក្សរដ្ឋមន្ត្រីក្រ




យ៉ាវ៉ា អាយុ៤៧ឆ្នាំ ជាសមាជិករដ្ឋសភាមានអាសយដ្ឋាននៅខណ្ឌទួលគោក រាជធានីភ្នំពេញ។ ទី២ លោក ស ចិត្រា អាយុ ៤៧ឆ្នាំ ជាអគ្គលេខាធិការរងនៃក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ ហើយម្នាក់ទៀតជាអគ្គរដ្ឋទូត ហុងគ្រី សំរាប់កម្ពុជា និងវៀតណាមដែលកំពុងស្នាក់នៅក្នុងសណ្ឋាគារមួយក្នុងទីក្រុងភ្នំពេញ។

ជុំវិញបញ្ហានេះ លោក ហ៊ុន សែន និងមន្ត្រីជាន់ខ្ពស់របស់លោកជាច្រើននាក់ទៀតដែលពាក់ព័ន្ធនឹងរដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសហុងគ្រី លោកភីធើស៊ីចាតូ (Peter Szijjarto) បាននាំគ្នាធ្វើតេស្តរកមេរោគកូវីដ១៩ ជាលើកទី២ នៅថ្ងៃទី៩ វិច្ឆិកានេះ។

សម្រាប់ការធ្វើតេស្តលើកទី១ បង្ហាញថា អ្នកជាប់ពាក់ព័ន្ធទាំងជិត១ពាន់នាក់នេះអវិជ្ជមានជម្ងឺកូវីដ១៩ ប៉ុន្តែពួកគេត្រូវធ្វើតេស្ត ជាលើកទី២ នៅថ្ងៃទី៩ ខែវិច្ឆិកា ហើយលើកទី៣ នៅថ្ងៃទី១៤ ខែវិច្ឆិកា និងលើកទី៤ នៅថ្ងៃទី១៨ ខែវិច្ឆិកា។

លើសពីនេះ ពួកគេ ព្រមទាំងរលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ផង តម្រូវឱ្យបន្តធ្វើចត្តាឡីស័កដោយខ្លួនចំនួន១៤ថ្ងៃ ដោយរង់ចាំលទ្ធផលធ្វើតេស្តរកកូវីដ-១៩លើក៣ និងលើកទី៤ ចេញជាផ្លូវការសិន។

រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មហុងគ្រី លោកភីធើស៊ីចាតូ ត្រូវបានគេរកឃើញមានកូវីដ-១៩ នៅពេលទៅដល់ប្រទេសថៃ។

សម្រាប់ការធ្វើតេស្តរកវីរុសកូវីដ-១៩ជាលើកសួងការបរទេសហុងគ្រី ជាជនជាតិខ្មែរម្នាក់បានឆ្លងកូវីដ១៩ និងបានសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

កន្លងមក លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានបញ្ជាឱ្យមន្ត្រី និងអ្នកពាក់ព័ន្ធករណីនេះទាំងអស់ត្រូវនាំគ្នាធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវជៀសវាងចេញក្រៅ ឬប្រាស្រ័យទាក់ទងជាមួយមនុស្សទី៣ ដែលធ្វើឱ្យលទ្ធភាពនៃការឆ្លងជំងឺកូវីដ១៩ រីករាលដាលចូលទៅក្នុងសហគមន៍។

ទំព័រហ្វេសប៊ុករបស់លោក ហ៊ុន សែន នៅថ្ងៃទី ៩ វិច្ឆិកានេះ បានឱ្យដឹងថា លោកនិងភរិយាបានដាក់ខ្លួនឯងឱ្យនៅដាច់ដោយឡែករយៈពេល ៤ថ្ងៃមកហើយ។

លោកអះអាងថា មកទល់ពេលនេះ លោក និងភរិយា ពុំមានឃើញនូវសញ្ញាណាមួយខុសប្រក្រតីនោះឡើយ ពោលគឺមានសុខភាពធម្មតា ដូចមុនថ្ងៃទី៣ ខែវិច្ឆិកា ឬមុនពេលជួបរដ្ឋមន្ត្រីក្រសួងការបរទេសហុងគ្រី។ តែទោះពីជាយ៉ាងណា លោក ហ៊ុន សែន បញ្ជាក់ថា លោកនៅតែបន្តធ្វើចត្តាឡីស័ក និងការធ្វើតេស្តតាមការកំណត់របស់ក្រសួងសុខាភិបាលតម្រូវ។ រីឯការធ្វើតេស្តជាលើកទី២ នេះ លោកសង្ឃឹមថា នឹងអវិជ្ជមានបន្តទៀត។

យ៉ាងណាលោក ហ៊ុន សែន បញ្ជាក់នៅរសៀលថ្ងៃច័ន្ទនេះថា ក្រុមគ្រូពេទ្យបានយកសំណាករបស់លោក និងភរិយា ព្រមទាំងអ្នកនៅជាមួយ និងអ្នកនៅជាប់លោកទាំងអស់ទៅធ្វើតេស្តជាលើកទី២ ហើយលទ្ធផល គឺអវិជ្ជមានភាគច្រើន។ យ៉ាងណា លោក ហ៊ុន សែន ត្រូវធ្វើចត្តាឡីស័កបន្តទៀត នឹងរង់ចាំការធ្វើតេស្តជាលើកទី៣ នៅថ្ងៃទី១៤ វិច្ឆិកា និងលើកទី៤ នៅថ្ងៃទី១៨ វិច្ឆិកា។

លើសពីនេះ លោកហ៊ុន សែន អះអាងថា លោកកំពុងរងចាំលទ្ធផលអ្នកធ្វើតេស្តនៅថ្ងៃនេះជិត១ពាន់នាក់ផ្សេងទៀត។

ប្រមុខរដ្ឋាភិបាលរូបនេះ ក៏បានអំពាវនាវចំពោះមនុស្សទាំងជិត១ពាន់នាក់ ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ឬ ដោយប្រយោលក្នុងដំណើរទស្សនៈកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការបរទេសហុងគ្រីបន្តធ្វើចត្តាឡីស័ក និងធ្វើតេស្តឱ្យបានហ្មត់ចត់តាមការណែនាំរបស់ក្រសួងសុខាភិបាល។

ដោយសារបញ្ហានេះហើយ ក្រសួងពាក់ព័ន្ធបានសម្រេចការបិទ គុទ្ធ ក្លឹបកម្សាន្ត រោង-ភាពយន្ត និងសារមន្ទីរ នៅទូទាំងប្រទេស សាជាថ្មីបន្ទាប់ពីអាជីវកម្មទាំងនេះបានបើកដំណើរការ ដោយគោរពតាមវិធានការសុវត្ថិភាពរបស់ក្រសួងសុខាភិបាលអស់រយៈពេលជាង៤ខែកន្លងមក។

ជាមួយគ្នានេះ ក្រសួងអប់រំបានសម្រេចឱ្យសាលារដ្ឋនិង ឯកជននៅក្រុងភ្នំពេញទាំងអស់សម្រាកពីរសប្តាហ៍ ដើម្បីបង្ការបញ្ហាកូវីដ១៩ពេលនេះផងដែរ។ គិតត្រឹមថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ នេះ កម្ពុជារកឃើញអ្នកមានវីរុសកូវីដ-១៩ ចំនួនសរុប២៩៧នាក់។ ក្នុងនោះ អ្នកជំងឺដែលត្រូវបានព្យាបាលជាសះស្បើយសរុបទូទាំងប្រទេសមានចំនួន២៨៨នាក់។ ដោយឡែកអ្នកជំងឺកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យនារាជធានីភ្នំពេញចំនួន៩នាក់។

## ខ្មាន់កាំភ្លើងបន្តបើកការបាញ់រះកក្រើកស្បែរាត្រីក្រុងព្រះសីហនុបង្កការភ័យខ្លាចដល់ប្រជាពលរដ្ឋ

By ឌឹ ខេមបូឌា ដេលី

- November 10, 2020

បទល្មើសបាញ់បោះសេរី បានបន្តកើតមានកក្រើកស្បែរាត្រីក្រុងព្រះសីហនុទៀតហើយៗ ក្រោយបង្កហេតុខ្មាន់កាំភ្លើងមិនស្គាល់អត្តសញ្ញាណ បានគេចខ្លួនដោយសុវត្ថិភាព ដោយមិនរំខានដំណោកសមត្ថកិច្ចនោះទេ។ កងរាជអាវុធហត្ថខេត្តនេះ ជួយពន្លឿនបើកការស៊ើបអង្កេត ឈានទៅនាំខ្លួនជនល្មើសមកផ្តន្ទាទោស។

យ៉ាងណាក៏ដោយចុះ គិតត្រឹមល្ងាចថ្ងៃសុក្រទី០៦ ខែវិច្ឆិកានេះ គេមិនទាន់ឃើញសមត្ថកិច្ចស្ថាប័នពាក់ព័ន្ធណាមួយបង្ហាញរបាយការណ៍លើករណីបាញ់រះបង្កការភ្ញាក់ផ្អើល ក្នុងក្រុងព្រះសីហនុនេះ



ប្រភពពីប្រជាពលរស់នៅក្រុងព្រះសីហនុ បានឱ្យដឹងថា នៅយប់ម៉ោង០១រំលងអាធ្រាត្រឈានចូលថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ មានករណីខ្មាន់កាំភ្លើងមិនស្គាល់អត្តសញ្ញាណម្នាក់ ដែលសង្ស័យជាជនជាតិចិន បានប្រើអាវុធខ្លីបាញ់រះប្រមាណ ១០ គ្រាប់ ទៅលើរថយន្តចំនួន០២គ្រឿង ដែលម្ចាស់ចតទុកនៅមុខសណ្ឋាគាររបស់ថៅកែជនជាតិចិនមួយកន្លែង ស្ថិតក្នុងសង្កាត់លេខ៤ ក្រុងព្រះសីហនុ មានទីតាំងជិត អាហារដ្ឋាន គីម ទ្រី។

ពលរដ្ឋរស់នៅក្រុងព្រះសីហនុ បន្តព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន ហើយស្នើដល់កម្លាំងសមត្ថកិច្ចស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ និងកម្លាំងនៅឡើយទេ។

ទោះជាបែបនេះក្តីយោងតាមការចុះផ្សាយរបស់គេហទំព័រក្នុងស្រុកឈ្មោះ "កម្ពុជាថ្ងៃនេះ" បានស្រង់សំដីមន្ត្រីសមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដែលស្នើមិនបញ្ចេញឈ្មោះមកចុះផ្សាយថា ករណីខ្មាន់កាំភ្លើងបាញ់រះ ទៅលើរថយន្តចំនួន ០២គ្រឿង ដែលម្ចាស់ចតទុក នៅមុខសណ្ឋាគារចិនក្រុងព្រះសីហនុ កម្លាំងជំនាញកំពុងបើកការស៊ើបអង្កេត និងកំណត់មុខសញ្ញាជនល្មើសបានខ្លះហើយ តាមរយៈកាមេរ៉ាសុវត្ថិភាព។

# ឌឹ ឃែមបូឌា ដេលី The Cambodia Daily

## អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី

### លោក ហ៊ុន សែន បញ្ជាឱ្យរដ្ឋមន្ត្រី និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវធ្វើចត្តាឡីស័កឱ្យបានច្បាស់លាស់

By ឌឹ ខេមបូឌា ដេលី

- November 10, 2020

លោក ហ៊ុន សែន បានចេញបទបញ្ជាទៅកាន់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី និងអ្នកពាក់ព័ន្ធដែលបានជួបដោយផ្ទាល់ឬប្រយោលជាមួយរដ្ឋមន្ត្រីក្រសួងការបរទេសនិងពាណិជ្ជកម្មនៃប្រទេសហុងគ្រី លោក ភីធើ ស៊ីចាតូ (Peter Szijjarto) ទាំងអស់ត្រូវធ្វើចត្តាឡីស័ក ឬដាក់ខ្លួនឱ្យនៅដាច់ដោយឡែកឱ្យបានច្បាស់លាស់ជៀសវាងការដាក់ខ្លួននៅ



ដាច់ដោយឡែកមិនបានត្រឹមត្រូវ ឬធ្វើសកម្មភាពជួបអ្នកដទៃ ដែលធ្វើឱ្យមានករណីឆ្លងជំងឺកូវីដ ១៩ ជាទ្រង់ទ្រាយធំ ឬចូលទៅក្នុងសហគមន៍។

សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលនៅថ្ងៃសុក្រទី៦ខែវិច្ឆិកានេះ បានឱ្យដឹងថា អ្នកប៉ះពាល់ជាមួយរដ្ឋមន្ត្រីការបរទេសហុងគ្រី លោក ភីធើ ស៊ីចាតូ (Peter Szijjarto) មានចំនួនរហូតទៅដល់ជិត១ពាន់នាក់(៨៤០)។

ក្រសួងបន្តថា ចំពោះលទ្ធផលតេស្តទៅលើអ្នកប៉ះពាល់ជាមួយរដ្ឋមន្ត្រីការបរទេសហុងគ្រីទាំងជិត១ពាន់នាក់កាលពីថ្ងៃម្សិលមិញនេះ ត្រូវបានវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបញ្ជាក់ថា អវិជ្ជមានវីរុសកូវីដ១៩ទាំងអស់។

ទោះជាយ៉ាងណាក្រសួងសុខាភិបាលបានណែនាំដល់អ្នកដែលប៉ះពាល់ទាំងនោះ វបន្តធ្វើចត្តាឡីស័កនៅតាមគេហដ្ឋានឱ្យបានត្រឹមត្រូវ និងត្រូវវិលត្រឡប់ទៅធ្វើតេស្តឡើងវិញចំនួន៣ដងទៀត នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី៩ ថ្ងៃទី១៤ និងទី១៨ ខែវិច្ឆិកា។

ក្នុងសារជាសំឡេងដែលត្រូវបានផ្សព្វផ្សាយនៅបណ្តាញសារព័ត៌មានដែលស្និតនឹងរដ្ឋាភិបាលឈ្មោះ Fresh New នៅថ្ងៃសុក្រនេះ លោកហ៊ុន សែន បានបញ្ជា ទៅឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី និងមន្ត្រីពាក់ព័ន្ធទាំងអស់ ត្រូវធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ។

ការបញ្ជានេះ ក្រោយពេលលោកសង្កេតឃើញថា មានមន្ត្រីខ្លះធ្វើចត្តាឡីស័កមិនបានត្រឹមត្រូវឡើយ ដោយខ្លះចេញក្រៅ ឬដើរហាត់ប្រាណ ឬជួបជាមួយមនុស្សទី៣ផ្សេងទៀត ហើយបញ្ហានេះលោកបារម្ភខ្លាចថា នឹងធ្វើឱ្យលទ្ធភាពនៃការចម្លងជំងឺកូវីដ១៩ ទៅកាន់សហគមន៍នឹងកើតមានឡើង ប្រសិនបើមន្ត្រី ឬអ្នកពាក់ព័ន្ធទាំងនោះ រកឃើញថាមានជំងឺកូវីដ១៩មែននោះ។

លោក ហ៊ុន សែន បញ្ជាក់ថា បញ្ជានេះ

រដ្ឋមន្ត្រីការបរទេសកម្ពុជា លោក ប្រាក់ សុខុន បានសន្ទនាតាមទូរស័ព្ទផ្ទាល់ជាមួយលោក លោក ភីធើ ស៊ីចាតូ រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មប្រទេសហុងគ្រី ខណៈលោក ភីធើ ស៊ីចាតូ ទៅដល់ប្រទេសហុងគ្រីវិញ ហើយកំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩ ។

ក្នុងកិច្ចសន្ទនាតាមទូរស័ព្ទលោក ភីធើ ស៊ីចាតូ បានសុំការអធ្យាស្រ័យចំពោះថ្នាក់ដឹកនាំកម្ពុជាអំពីផលប៉ះពាល់នៃជំងឺកូវីដ១៩ បណ្តាលមកពីខ្លួនគាត់ ដែលលោកបានធ្វើតេស្ត មិនមានកូវីដ១៩នោះទេ ទើបលោកបានដឹកនាំគណៈប្រតិភូចេញមកបំពេញទស្សនកិច្ចនៅកម្ពុជា។

យ៉ាងណាក៏ដោយ គេនៅមិនទាន់ឃើញមានប្រភពច្បាស់លាស់ណាមួយ ដែលបញ្ជាក់ថា លោក ភីធើ ឆ្លងកូវីដ-១៩ តាំងពីពេលណា និងនៅទីណានោះទេ។

ដោយឡែកក្រសួងការបរទេសកម្ពុជា អះអាងថា លោក ភីធើ និងសមាជិកគណៈប្រតិភូទាំងអស់របស់លោកបានធ្វើតេស្តរកមេរោគកូវីដ-១៩ និងមានវិញ្ញាណបនបត្រសុខភាព ដែលបញ្ជាក់ពីការគ្មានជំងឺកូវីដ-១៩ មុនពេលចេញដំណើរមកកម្ពុជា។

លោក ភីធើ និងគណៈប្រតិភូរបស់លោកបានមកដល់កម្ពុជានៅព្រឹកថ្ងៃទី៣ ខែវិច្ឆិកា ដើម្បីបំពេញទស្សនកិច្ចផ្លូវការ ហើយនៅពេលល្ងាចក្នុងថ្ងៃដដែល ហើយលោក និងគណៈប្រតិភូ ក៏បានចេញពីកម្ពុជាបន្តដំណើរទៅបំពេញបេសកកម្មការទូតនៅប្រទេសថៃ។

ពេលទៅដល់ថៃ ក៏មានព័ត៌មាន ផ្សាយនៅថ្ងៃទី៤ ខែវិច្ឆិកា ថា លោក ត្រូវធ្វើតេស្តរកឃើញថា មានជំងឺកូវីដ-១៩ ហើយបន្ទាប់មក រដ្ឋាភិបាលរបស់លោកបានបញ្ជូនយន្តហោះ ដឹកលោកទៅហុងគ្រីវិញ ដោយជំនួបនានារបស់លោក និងមេដឹកនាំថៃត្រូវលុបចោលភ្លាម១ផងដែរ។

ក្នុងអំឡុងទស្សនកិច្ចនៅកម្ពុជា រដ្ឋមន្ត្រីការបរទេសហុងគ្រីលោក ភីធើ ស៊ីចាតូ និងគណៈប្រតិភូរបស់លោកបានជួបថ្នាក់ដឹកនាំកម្ពុជាមួយចំនួន រួមមានលោក ហ៊ុន សែន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាលោក ប្រាក់ សុខុន។ ជួបជាមួយរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយមលោក លឹម គានហោ។ ជួបជាមួយរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ លោក វេង សាខុន និង ជួបជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មលោក ប៉ានសូរស័ក្តិ ព្រមទាំងថ្នាក់ដឹកនាំកម្ពុជាច្រើនរូបផ្សេងទៀត។

### មេដឹកនាំបក្សប្រឆាំង បួងសួង ឱ្យកម្ពុជាមាន ឯករាជ្យ-ជាតិពិត និងបិតបេរជារៀងរហូត

By ឌឹ ខេមបូឌា ដេលី

- November 10, 2020

ប្រធានគណបក្សប្រឆាំងកំពុងរងការរឹតត្បិតសេរីភាពលោក កឹម សុខា អះអាងថា សាមគ្គីភាពជាតិនាំមកនូវឯករាជ្យជាតិរឹងមាំ ហើយដើម្បីការពារឯករាជ្យជាតិ លុះត្រាតែកាត់បន្ថយមហិច្ឆតាផ្ទាល់ខ្លួនមិនគុំគួន ងាកមករកការអត់ឱនឱ្យគ្នា ចាប់យកការសន្ទនា បោះបង់ចោលការប្រមាថ ឈប់បង្កជម្លោះរវាងជាតិឯងតទៅទៀត។

ប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា បានសរសេរនៅលើទំព័រហ្វេសប៊ុករបស់លោកនៅថ្ងៃនេះថា ប្រទេសជាតិណាក៏ចង់បានឯករាជ្យ មិនចង់ស្ថិតនៅក្រោមអាណានិគម ឬធ្វើជាខ្ញុំកញ្ជះ



គេនោះទេ។ ដូច្នេះលោកថា ការបែកបាក់សាមគ្គីជាតិ នាំឱ្យប្រទេសជាតិទន់ខ្សោយ ហើយនឹងនាំឱ្យបាត់បង់ឯករាជ្យជាតិនៃប្រទេសនោះទៀតផង។

លោកថា បើសូម្បីតែការរក្សាភាពអត់ធ្មត់ស្ងប់ស្ងាត់មិនឈ្លោះ មិនឆ្លើយ មិនឆ្លង និងចូលរួមធ្វើសកម្មភាពមនុស្សធម៌ ដូចជាប្រឆាំងនឹងជម្ងឺឆ្លងកូវីដ-១៩ និងជួយសង្គ្រោះពលរដ្ឋរងគ្រោះដោយទឹកជំនន់ ក៏នៅតែដាក់កំហុសដែរ នោះជា គឺសញ្ញាបង្ហាញថាមិនអាចកើតមានសាមគ្គីភាពជាតិបានទេ ហើយក៏មិនអាចមានឈ្មោះថាជាអ្នកទាមទាររក្សា ការពារ ឯករាជ្យជាតិពិតប្រាកដនោះដែរ។

លោក កឹម សុខា បញ្ជាក់ថា សង្គមមួយ ឬប្រទេសជាតិមួយ ដែលបែកបាក់សាមគ្គីភាពផ្ទៃក្នុង គឺជាការផ្តល់ឱកាសឱ្យអ្នកខាងក្រៅងាយចូលមកទាញយកផលប្រយោជន៍ ត្រួតត្រា និងបំផ្លិចបំផ្លាញជាតិ ជាពិសេសអាចធ្វើឱ្យអាប់ឱនកិត្តិយសនិងកេរ្តិ៍ឈ្មោះជាតិទាំងមូលទៀតផង។

ការអះអាងនេះធ្វើឡើងក្នុងឱកាស អបអរសាទរ ប្រារព្ធទិវាខួបលើកទី៦៧ នៃទិវាបុណ្យឯករាជ្យជាតិខ្មែរ ៩ វិច្ឆិកា នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២០ នេះ។

លើកឡើងក្នុងទិវា អបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៧ នៃទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកានេះដែរ ប្រមុខរដ្ឋាភិបាលកម្ពុជាលោក ហ៊ុន សែន បញ្ជាក់ថា ទិវាបុណ្យឯករាជ្យជាតិ ៩វិច្ឆិកានេះ បានរំលឹកឱ្យឃើញពីព្រះរាជបេសកកម្មដើម្បីជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែររបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបិតាឯករាជ្យជាតិព្រះបរមរតនកោដ្ឋ។

តមកពីទំព័រទី ០៤

# អបអរសាទ ជោ បាយដិន ជាប្រធានាធិបតី

ហេតុនេះនឹងជួសជុលសម្ព័ន្ធភាពនៅអាស៊ី ជួសជុលនៅអ.ស.ប. -ជួសជួលនៅសហភាពអឺរ៉ុប ជួសជុលទំនាក់ទំនងសេដ្ឋវិមាន-FBI ជាពិសេស គ្រប់គ្រងការកំចាត់"កូវីដ១៩"ដែលបានសម្លាប់បងប្អូនអាមេរិកាំងជិត២៣ម៉ឺននាក់ទៅហើយ ។

យ៉ាងណាមិញការបោះឆ្នោតលើកនេះ ស្ទើរតែមិនមែន ជាការប្រជែងជាមួយ ជោ បាយដិន ទេ តែជាការវិនិច្ឆ័យស្នាដៃ៤ឆ្នាំ របស់ ឌុណល ត្រាំ ដែលសម្បូរទៅដោយភូតភរ ប្រកាន់ពូជសាស្ត្រ ធ្វើឱ្យសហរដ្ឋអាមេរិកចុះខ្សោយចំពោះមុខកុម្មុយនិស្តនឹងទន់ខ្សោយចំពោះមុខជម្ងឺ"កូវីដ១៩" ទៅវិញប៉ុណ្ណោះ ។ ដូច្នេះការខិតខំចង់ជួយជាតិរបស់សហគមន៍ខ្មែរយើង ជាមួយ បាយដិន នឹងមិនខុសនោះទេ ។

**ជោគជ័យនៃស្ត្រីនឹងអាស៊ីនៃ កាម្លា ហារីស**

លោកស្រី កាម្លា ហារីស បានចូលក្នុងប្រវត្តិសាស្ត្រ ដោយសារជាស្ត្រីដំបូង មានដើមកំណើតជាស្ត្រីអាហ្វ្រិកាំង-ពាក់កណ្តាលអាស៊ី ដែលមានឋានៈជាអនុប្រធានាធិបតីនៃប្រទេសអាមេរិក កំពូលពិភពលោក ឥឡូវមានភារៈកិច្ច ជាអ្នកមកជួយស្តារពិភពលោក ។ លោកស្រីធ្លាប់ធ្វើជាអគ្គរដ្ឋអាជ្ញា, ជាព្រឹទ្ធសមាជិកសហរដ្ឋអាមេរិក មានប្រាជ្ញាឈ្លៀសវៃ បានឈរឈ្មោះជាបេក្ខនារីប្រធានាធិបតីតែបានថយខលួនវិញ ដែលបន្ទាប់មកលោក បាយដិន នៅពេលជាប់ជាបេក្ខជនប្រធានាធិបតីផ្លូវការ បានចាប់យកលោកស្រីហារីស មកជាដៃគូរនយោបាយផ្លូវការ សម្រាប់ដំណែងដ៏ខ្ពស់បំផុតនៅសហរដ្ឋអាមេរិក ។

គេអាចយល់បានភ្លាមថា លោកស្រីជាប់ឆ្នោតដោយសមត្ថភាពខ្លួនឯង គឺឆ្នោតស្ត្រីអា



ស៊ី និង ពូទីន មិនបានអបអរសាទនឹងជ័យជំនះ បាយឌិន នៅឡើយទេ

មេរីកាំងដែលមិនចង់បន្តរការបន្ទាបតម្លៃស្ត្រី -ឆ្នោតពលរដ្ឋស្បែកខ្មៅនឹងប្រផេះ នឹងឆ្នោតអតីតជនអន្តោប្រវេសន៏ ដែលប្រឆាំងការលើកដំកើងហួសហេតុនៃជនស្បែកសនឹងការប្រឆាំងជាស្វ័យប្រវត្តិចំពោះជនអន្តោប្រវេសន៏ ។

កាម្លា ហារីស ជាមួយនឹងប្រធានាធិបតី បាយដិន នឹងបើកទំព័រថ្មីនៃនយោបាយសន្តិសុខពិភពលោកបង្កើតសម្ពន្ធភាពជាមួយប្រទេសសេរីឡើងវិញ ជាពិសេសដើម្បីលំនឹងនៃភូមិភាគអាស៊ីប៉ាស៊ីហ្វិក នៃភូមិភាគអាហ្វ្រិក្រ នឹងភូមិភាគឥណ្ឌា ...ឡើងវិញ ។ ពិភពលោកកំពុងតែរំពឹងនឹងរង់ចាំសកម្មភាពនៃមេដឹកនាំកំពូលដ៏ថ្មីស្រឡាងទាំង២នេះហើយ, ប៉ុន្តែមេដឹកនាំផ្តាច់ការនៅកម្ពុជា ក៏ដូចជានៅប្រទេសចិន គេគាំទ្រលោកត្រាំ ហើយពុំបានគាំទ្រលោក ជោ បាយដិន-កាម្លា ហារីសទេ ។

**បោះឆ្នោតសភាដំណាងរាស្ត្រនឹងព្រឹទ្ធសមាជិក**

នៅថ្ងៃបោះឆ្នោត៣វិច្ឆិកា ក៏មានការបោះឆ្នោតរើសដំណាងរាស្ត្រនឹងព្រឹទ្ធសមាជិកដែរ ដែល១ភាគ៣ត្រូវចប់អាណត្តិ ។ ដោយសារតែការរាប់សន្លឹកឆ្នោតមិនទាន់ចប់ គេក៏ពុំទាន់ដឹងលទ្ធផលពិតប្រាកដនៅឡើយទេ ។

ហេតុផល៣យ៉ាង ដែលគេអាចសន្និដ្ឋានបានថា ជោ បាយដិន នឹងទទួលបាននូវស្ថាប័នសភាដំណាងរាស្ត្រជាន់ទាប នឹងស្ថាប័នព្រឹទ្ធសភាជាន់ខ្ពស់ នៅខាងគណបក្សប្រជាធិបតេយ្យ គឺ **១**-ជ័យជំនះរបស់ជោបាយដិន នឹងកាម្លា ហារីស បានជះចំហាយគណបក្សប្រជាធិបតេយ្យ ជួយឱ្យសមាជិករបស់ខ្លួនឈ្នះឆ្នោតបាន **២**-គណបក្សប្រជាធិបតេយ្យឈ្នះនឹងរក្សាអាសនៈភាគច្រើននៅសភាដំណាងរាស្ត្រឱ្យនៅដដែលបាន **៣**-ដោយសារលោកប្រធានាធិបតីចេញ ឌុណល ត្រាំ មិនព្រមកែរតម្រូវនយោបាយប្រញាប់របស់ខ្លួន ហើយនៅតែចចេស ធ្វើឱ្យអ្នកបោះឆ្នោតនឹងបេក្ខជនរបស់ខ្លួនងាករេទៅរកទស្សនៈដើមនៃគណបក្សសាធារណរដ្ឋ ដែលនៅជិតលោក ជោ បាយដិន ជាង ។ ការកែរប្រែនេះនឹងធ្វើឱ្យរបូតអាសនៈនៅព្រឹទ្ធសភាជាន់ខ្ពស់ខ្លះ អាចនាំឱ្យគណបក្សប្រជាធិបតេយ្យយកអាសនៈភាគច្រើនវិញបានតែមិនរបូតទាំងអស់( ៣៣ អាសនៈ) ទេ ។

**សហគមន៍អន្តរជាតិទទួលអបអរនឹងប្រធានាធិបតីថ្មី**

ប្រធានសហភាពអឺរ៉ុប នឹងប្រធានាធិបតីនៃប្រទេសក្នុងអឺរ៉ុបខ្លះដែលសម្តែងការអបអរនឹងប្រធានាធិបតីអាមេរិកថ្មី ដែលគេថានឹងបានបញ្ចប់ភាពក្រអឺតក្រទមនៃសហរដ្ឋអាមេរិក ។ ចក្រភពអង់គ្លេស ដែលចាកចេញពីអឺរ៉ុប តែប្រកាន់ជិត ត្រាំ ពុំទាន់ដឹងថាត្រូវធ្វើយ៉ាងណានៅឡើយទេ ។



# THE LRTA IS NOW HIRING A FULL-TIME MECHANIC



Must be 21 years old or older
with a clean driving record
Must have your own tools
Minimum of 2 years
technician experience

**CDL-B license is a plus but not required**
**Other LRTA requirements may apply**

*Competitive Pay Rate • Medical & Life Insurance*
*401K • And More!*

**Please send resume to Director of Maintenance at**
**100 Hale Street, Lowell, MA 01851**
**or Email to customerservice@LRTA.com**
**For more information call: 978-452-6161 ext. 214**

Lowell Regional Transit Authority
**An Equal Opportunity Employer**

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត

## URBAN REAL ESTATE

មជ្ឈមណ្ឌលផ្តល់សេវា
ជួលលំនៅដ្ឋាន

**Residential Leasing Center**



ដាញ៉េល តាន
ភ្នាក់ងារអចលនៈទ្រព្យ

**Daniel Tan**
**Real Estate Agent**
**Cell: 978-902-6354**

**508 Westford Street • Lowell, MA 01851**
**(978) 454-0444**

ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី

## KK Insurance Agency, Inc.

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម

**Car • Home • Business**

**508 Westford Street**
**Lowell, MA 01851**
**978-970-2212**
**kk@kkinsurancema.com**





## KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



**អគ្គនាយក សុបិន្ទ ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com

**ផ្សាយពាណិជ្ជកម្ម សុបិន្ទ ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com
**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

**បើលោកអ្នកមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។**

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មានសំបុត្រ ហេលស្ទែនដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក
## To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852




# អបអរសាទទិវាបុណ្យឯករាជ្យ ៩វិច្ឆិកា ១៩៥៤

ដោយ : ពិន សំខុន



រំលឹកបុណ្យឯករាជ្យឆ្នាំ៩វិច្ឆិកា ១៩៥៤ ជាអំពើត្រឹមត្រូវមួយ ដែលប្រជាពលរដ្ឋ និងយោធាអ្នកនយោបាយបានខំប្រឹងប្រែងការពារប្រទេសកម្ពុជា អោយសល់១៨១០៣៥គីឡូម៉ែត្រការ៉េ នៃបូរណភាពប្រទេសកម្ពុជា ។

ក្រោមការដឹកនាំរបស់សម្តេចនរោត្តម សីហនុ ជាស្តេចក្រុងកម្ពុជា ព្រះអង្គបានឆ្លងកាត់គ្រប់ឧបសគ្គតាំងពីឆ្នាំ១៩៤០ ទើបបានឯករាជ្យនៅឆ្នាំ១៩៥៤ ។ *សូមអានអត្ថបទរំលឹកបុណ្យឯករាជ្យនៅលេខក្រោយ*










ការពារគ្រួសាររបស់អ្នកនៅផ្ទះ
មនុស្សវ័យចំណាស់ និងអ្នកដែលមានលក្ខណៈគ្រាំគ្រែង ដូចជាជំងឺទឹកនោមផ្អែម
និងជំងឺហឺត គឺបានកើនហានិភ័យពីជំងឺ COVID-19។
ការជូតសំអាត
ជូតសំអាតផ្ទៃដែលប៉ះច្រើន ជាប្រក្រតី
ON
OFF
គន្លឹះបិទបើកភ្លើង
ដៃទ្វារ
ដៃទូទឹកកក
ផ្ទៃបន្ទប់ទឹក
(ក្បាលបិទបើកទឹក និងដៃបង្គន់)
ពេលបរិភោគអាហារ
6’
អង្គុយចំងាយ 6 ហ្វីតពីគ្នា ឬដូរវេនគ្នាបរិភោគ
កុំចែកចាយអាហារពីចានដូចគ្នា ឬចែកចាយភេសជ្ជៈគ្នា
ខាងក្នុង និងខាងក្រៅ
ពាក់ម៉ាស្កនៅខាងក្នុង នៅពេល
មិនអាចឃ្លាតពីគ្នា 6 ហ្វីតបាន
ពាក់ម៉ាស្កនៅខាងក្រៅផ្ទះ
 លាងដៃនៅពេលត្រឡប់មកផ្ទះ
ជៀសវាងដេកនៅក្នុងបន្ទប់ដូចគ្នា
ស្វែងយល់ថែមទៀតនៅ Mass.gov/បញ្ឈប់COVID១៩
SIGILLUM REIPUBLICÆ MASSACHUSETTENSIS